ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ៧៩១ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ 2006

## ប្រកាស
## ស្ដីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ
## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា.
- បានឃើញព្រះរាជក្រមលេខ / នស.រកម / ០១៩៧ / ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន.
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា.
- បានឃើញប្រកាសលេខ ៣៥៩ សអយ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត-ក្រុង.
- បានឃើញប្រកាសលេខ ៧៩០ សអយ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦ ស្ដីពីការបង្កើតមជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់.

## សម្រេច

**ប្រការ១ :** ប្រកាសនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ មជ្ឈមណ្ឌលនេះមានតួនាទី ទទួលយកអ្នកញៀនគ្រឿង

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd , Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

ញៀន គ្រប់វ័យ គ្រប់ភេទ មកគ្រប់គ្រង ព្យាបាល អប់រំបណ្តុះបណ្តាល និង សមាហរណកម្មទៅក្នុងសហគមន៍វិញ ។

**ប្រការ២ :** មជ្ឈមណ្ឌលនេះមានតួនាទី និងភារកិច្ចដូចតទៅ :

**ក. ការទទួល និងគ្រប់គ្រង :**

- សហការជាមួយអាជ្ញាធរដែនដី អង្គភាពមានសមត្ថកិច្ច មាតាបិតា អាណាព្យាបាល អង្គការមិនមែនរដ្ឋាភិបាល ទទួលយកជនរងគ្រោះទាំងពីរភេទ ដូចមានចែងក្នុងប្រការ១ មកគ្រប់គ្រង ។
- លើកសំណើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីសុំទទួលយក អ្នកញៀនគ្រឿងញៀន មកព្យាបាល និងស្តារនីតិសម្បទា
- ធ្វើកោសល្យវិច័យ ពិគ្រោះយោបល់ បំពេញទំរង់បែបបទឯកសារពាក់ព័ន្ធសាមីខ្លួន
- រៀបចំការស្នាក់នៅរបស់ជនរងគ្រោះតាមវ័យ តាមភេទ និងតាមប្រភេទបញ្ហា
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌល ស្របតាមបទបញ្ញត្តិផ្សេងៗរបស់រដ្ឋ ដោយមានការឯកភាពពីក្រសួង.

**ខ. ការងារព្យាបាលស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម :**

- ព្យាបាល ថែទាំសុខភាព ផ្គត់ផ្គង់ជីវភាព តាមរបបកំណត់របស់មជ្ឈមណ្ឌល និងជំនួយឧបត្ថម្ភពីមជ្ឈដ្ឋាននានា.
- ផ្តល់ប្រឹក្សា
- ផ្តល់ការអប់រំសីលធម៌ សុខភាព ផ្លូវចិត្ត បំណិនជីវិត
- បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈស្របទៅតាមទីផ្សារការងារ ក្រោយពីអ្នកញៀនគ្រឿងញៀនមានភាពធូរស្បើយ.
- រៀបចំសកម្មភាព ហាត់ប្រាណ វប្បធម៌ សិល្បៈ កីឡា និងការកំសាន្តផ្សេងៗ
- ត្រួតពិនិត្យ តាមដានដំណើរការវិវត្តរបស់ជនរងគ្រោះ នៅក្នុងមជ្ឈមណ្ឌល
- ផ្តល់លិខិតទទួលស្គាល់មុខជំនាញពេលប្រឡងបញ្ចប់វគ្គ
- លើកសំណើសុំធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនដែលបានជាសះស្បើយ ទៅក្រុមគ្រួសារ អាណាព្យាបាល និងសហគមន៍វិញ.
- ទំនាក់ទំនងជាមួយក្រុមគ្រួសារ អាណាព្យាបាល ដើម្បីទទួលយកជនរងគ្រោះត្រឡប់ទៅក្រុមគ្រួសារ និងសហគមន៍វិញ.
- រៀបចំបែបបទបញ្ជូនជនរងគ្រោះទៅក្រុមគ្រួសារ អាណាព្យាបាល និងសហគមន៍វិញ.

**ប្រការ៣ :** មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវបានដឹកនាំ ដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ មានរចនាសម្ព័ន្ធដូចតទៅ :**

១- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ.

២- ផ្នែកទទួល និងគ្រប់គ្រង.

៣- ផ្នែកព្យាបាលស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន.

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប និងអនុប្រធានពីររូបជាជំនួយការ ។

***តួនាទី និងភារកិច្ចរបស់ផ្នែកនីមួយៗ មានដូចខាងក្រោម :***

**១- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ :**

***ជាជំនួយការរបស់មណ្ឌល ទទួលបន្ទុក :***

- លិខិតចេញ-ចូល
- ការងារតំកល់ឯកសារ
- រៀបចំកាលវិភាគប្រចាំថ្ងៃ
- រៀបចំសន្តិសុខ សណ្តាប់ធ្នាប់ នៅក្នុងមជ្ឈមណ្ឌល
- កសាងលិខិតរដ្ឋបាលផ្សេងៗ
- ពិធីការ អនាម័យ
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- មន្ត្រីបុគ្គលិក ជីវប្រវត្តិ
- គ្រប់គ្រងសំភារៈបរិក្ខារ ចលនទ្រព្យ អចលនទ្រព្យ របស់មជ្ឈមណ្ឌល
- ថវិកា បៀវត្ស មន្ត្រីបុគ្គលិក
- ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ របស់មជ្ឈមណ្ឌល
- ធ្វើគំរោងថែទាំ ជួសជុលអាគារ មធ្យោបាយដឹកជញ្ជូន និងសំភារៈផ្សេងៗ
- ធ្វើរបាយការណ៍ ការប្រើប្រាស់ថវិកាតាមកាលកំណត់ ។

**២- ផ្នែកទទួល និងគ្រប់គ្រង :**

***ជាជំនួយការរបស់មណ្ឌល ទទួលបន្ទុក :***

- គ្រប់គ្រងស្ថិតិអ្នកញៀនគ្រឿងញៀន
- អនុវត្តនីតិវិធីទទួល
- ធ្វើកោសល្យវិច័យ សាកសួរកត់ត្រាជីវប្រវត្តិ
- បែងចែកសំលៀកបំពាក់ និងការស្នាក់នៅ តាមដំណាក់កាល វ័យ ភេទ
- ត្រួតពិនិត្យដំណើរការវិវឌ្ឍន៍របស់អ្នកញៀនគ្រឿងញៀន ។

**៣- ផ្នែកព្យាបាលស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន :**

***ជាជំនួយការរបស់មជ្ឈមណ្ឌល ទទួលបន្ទុក :***

- ផ្តល់ប្រឹក្សា ពិគ្រោះយោបល់
- រៀបចំកម្មវិធីព្យាបាលសុខភាព បន្សាបជាតិពុល
- រៀបចំសកម្មភាព ហាត់ប្រាណ
- អនុវត្តកម្មវិធីសិក្សា អប់រំសីលធម៌ អប់រំសុខភាព អប់រំច្បាប់ និងផលប៉ះពាល់ នៃការប្រើប្រាស់បំពាន

គ្រឿងញៀន.

- បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ
- បែងចែកការសិក្សា និងបំពាក់បំប៉នវិន័យសិក្សាក្រៅប្រព័ន្ធ
- គ្រប់គ្រងបណ្ណាល័យ ថ្នាក់រៀន រោងជាង
- រៀបចំកម្មវិធីសំរួលដល់គ្រូ និងអ្នកឯកទេសផ្សេងៗ
- រៀបចំសកម្មភាព វប្បធម៌ សិល្បៈ កីឡា និងសាសនា
- ធ្វើរបាយការណ៍អំពីការសិក្សា និងការបង្ហាត់បង្រៀន
- រៀបចំការប្រលងបញ្ចប់វគ្គ និងផ្តល់លិខិតបញ្ជាក់ការសិក្សា
- លើកសំណើធ្វើសមាហរណកម្ម
- សម្របសម្រួលការងារធ្វើសំរាប់អ្នកញៀនគ្រឿងញៀន ដែលបានធ្វើសមាហរណកម្ម
- ត្រួតពិនិត្យ តាមដាន និងអន្តរាគមន៍អ្នកញៀនគ្រឿងញៀន ដែលបានសមាហរណកម្មទៅក្នុងសហគមន៍

**ប្រការ៤ :** នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានយុវនីតិសម្បទា ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ និងប្រធានមជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់មានភារកិច្ចរៀងៗខ្លួន អនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សាលាខេត្តបន្ទាយមានជ័យ " ដើម្បីជូនជ្រាប "
- ដូចប្រការ៣ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ